# មន្ទីរព្យាបាលសង្គ្រោះបន្ទាន់ (ED)

Khmer

## អ្វីដែលត្រូវរំពឹង ក្នុងអំឡុងពេលអញ្ជើញមកដល់របស់អ្នក

### ការចុះឈ្មោះ (ព័ត៌មានអំពីអ្នក)

**នៅពេលអ្នកអញ្ជើញមកមន្ទីរព្យាបាលសង្គ្រោះបន្ទាន់ (ED)**

- យើងនឹងសួរឈ្មោះ អាសយដ្ឋាន និងព័ត៌មានលម្អិតផ្សេងទៀតរបស់អ្នក
- គិលានុបដ្ឋាកនឹងសួរអំពីសុខភាពរបស់អ្នក ហើយមូលហេតុបានជាអ្នកមកទីនេះ

**សូមកុំបរិភោគ ឬពិសាទឹក** ពេលអ្នកកំពុងរង់ចាំជួបគិលានុបដ្ឋាក។

យើងប្រហែលជាមិនអាចធ្វើតេស្តខ្លះបានទេ ប្រសិនបើអ្នកបានបរិភោគរួចហើយ។

### កំពុងរង់ចាំ

- មនុស្សជាច្រើនអញ្ជើញមកកាន់ ED ដូច្នេះអ្នកប្រហែលជាត្រូវរង់ចាំយូរ
- មនុស្សដែលឈឺបំផុតត្រូវបានគេពិនិត្យមុនគេ មិនមែនមនុស្សដែលមកដល់ទីនេះមុនគេទេ
- អ្នកនឹងត្រូវរង់ចាំ ប្រសិនបើអ្នកធ្វើតេស្ត ឬស្កែន
- យើងនឹងថែទាំអ្នក ខណៈពេលអ្នកកំពុងនៅរង់ចាំ
- សូមប្រាប់បុគ្គលិករបស់យើង ប្រសិនបើអ្នកមានការឈឺចាប់ ឬប្រសិនបើអ្នកចាប់ផ្តើមមានអារម្មណ៍មិនល្អ

**ពេលម៉ោងរង់ចាំអាចផ្លាស់ប្តូរ ខណៈពេលអ្នកកំពុងស្ថិតនៅ ED។ ការនេះអាចកើតឡើង ប្រសិនបើអ្នកជំងឺមកដល់ក្នុងរថយន្តសង្គ្រោះបន្ទាន់។**

### ប្រសិនបើអ្នកមានការព្រួយបារម្ភ ខណៈពេលអ្នកកំពុងរង់ចាំ

- មិនអីទេក្នុងការសួរសំណួរ ប្រសិនបើអ្នកមិនយល់ដឹងពីអ្វីដែលកំពុងកើតឡើង
- សូមសួរវេជ្ជបណ្ឌិតរបស់អ្នក គិលានុបដ្ឋាក ឬគិលានុបដ្ឋាកដែលទទួលខុសត្រូវ (ពាក់បន្ទះខ្សែដៃពណ៌ក្រហម និងស)
- សូមប្រាប់យើង ប្រសិនបើវាអាចជួយក្នុងការនិយាយជាមួយយើងជាភាសាផ្សេងទៀត - យើងអាចជួយរៀបចំអ្នកបកប្រែផ្ទាល់មាត់។

ប្រសិនបើអ្នកនៅតែព្រួយបារម្ភ សូមទូរសព្ទ ហើយស្នើសុំនិយាយជាមួយអ្នកសម្របសម្រួលគិលានុបដ្ឋាកៈ

- **មន្ទីរពេទ្យ Casey Hospital** 8768 1579
- **មន្ទីរពេទ្យ Medical Centre** 9594 2717
- **មន្ទីរពេទ្យ Hospital** 9554 8329

Interpreter

## សម្រាប់អ្នកបកប្រែផ្ទាល់មាត់ សូមទូរសព្ទលេខ

**131 450 TIS National**

ស្កេនលេខ កូដ QR សម្រាប់ភាសា ផ្សេងទៀត

# មន្ទីរព្យាបាលសង្គ្រោះបន្ទាន់ (ED)

## នៅខាងក្នុងមន្ទីរព្យាបាលសង្គ្រោះបន្ទាន់

- អ្នកនឹងត្រូវបានពិនិត្យដោយវេជ្ជបណ្ឌិត គិលានុបដ្ឋាក ឬអ្នកដែលបានបណ្តុះបណ្តាលយ៉ាងពិសេសដើម្បីជួយអ្នក។
- អ្នកប្រហែលជាត្រូវធ្វើតេស្ត ឧទាហរណ៍ ការធ្វើតេស្តឈាម ឬថតកាំរស្មីអ៊ិក្ស។
- អ្នកប្រហែលជាត្រូវផ្លាស់ទី ទៅកាន់តំបន់ផ្សេងៗនៅក្នុងមន្ទីរពេទ្យ៖
  - សម្រាប់ការធ្វើតេស្ត
  - រង់ចាំលទ្ធផលតេស្ត
  - សម្រាប់ការព្យាបាល
- ប្រសិនបើអ្នកអាចព្យាបាលនៅក្នុង ED អ្នកគួរតែអាចត្រឡប់ទៅផ្ទះវិញបន្ទាប់ពីការព្យាបាល។

## ខណៈពេលដែលអ្នកកំពុងត្រូវបានគេពិនិត្យ និងព្យាបាល

- ក្រុមគ្រួសាររបស់អ្នកប្រហែលជាត្រូវរង់ចាំនៅកន្លែងផ្សេង ខណៈពេលអ្នកនៅទីនេះ។
- យើងនឹងប្រាប់ក្រុមគ្រួសាររបស់អ្នកអំពីអ្វីដែលកំពុងកើតឡើង ហើយនាំពួកគេមកជួបអ្នកឱ្យបានឆាប់ដែលអាចធ្វើ

## ប្រសិនបើអ្នកត្រូវស្នាក់នៅមន្ទីរពេទ្យដើម្បីទទួលការព្យាបាល

- ប្រសិនបើយើងត្រូវការបន្តត្រួតពិនិត្យអ្នករហូតដល់ទៅ 24 ម៉ោង អ្នកប្រហែលជាត្រូវចូលទៅ **មន្ទីរស្នាក់នៅរយៈពេលខ្លី (SSU)** របស់យើង។
- ប្រសិនបើអ្នកមិនត្រូវការការព្យាបាលបន្ថែមទេបន្ទាប់ពី 24 ម៉ោង អ្នកគួរតែអាចត្រឡប់ទៅផ្ទះវិញពី មន្ទីរស្នាក់នៅរយៈពេលខ្លី (សូមអានអំពី 'ការត្រឡប់ទៅផ្ទះវិញ')។

## ការចុះឈ្មោះអ្នកជំងឺឱ្យស្នាក់នៅក្នុងមន្ទីរពេទ្យ

- ប្រសិនបើអ្នកត្រូវការការថែទាំបន្ថែម ឬការព្យាបាល ឬការធ្វើតេស្តបន្ថែម អ្នកប្រហែលជាត្រូវបានចុះឈ្មោះ ឱ្យស្នាក់នៅក្នុងមន្ទីរពេទ្យ។
- អ្នកអាចរង់ចាំនៅ ED រហូតដល់គ្រែមួយមានផ្តល់ជូនអ្នក។

## ការត្រឡប់ទៅផ្ទះវិញ

- នៅពេលអ្នកអាចត្រឡប់ទៅផ្ទះវិញនេះ ត្រូវបានគេហៅថា 'ការឱ្យចាកចេញពីមន្ទីរពេទ្យ'។
- ប្រសិនបើអ្នកត្រូវលេប**ថ្នាំពេទ្យថ្មី** វាសំខាន់ខ្លាំងណាស់ដែលអ្នកត្រូវយល់ដឹងអំពីថ្នាំទាំងនេះគឺសម្រាប់អ្វី និងរបៀបប្រើវា។ សូមសួរយើងឱ្យបានច្រើន តាមដែលអ្នកត្រូវការ។
- ស្នើសុំឱ្យគិលានុបដ្ឋាក កត់ត្រានូវអ្វីដែលអ្នកត្រូវធ្វើបន្ទាប់។ នេះអាចជាការណាត់ជួបជាមួយវេជ្ជបណ្ឌិតរបស់អ្នកផ្ទាល់ ឬត្រឡប់មក ED វិញ ប្រសិនបើអ្នកឈឺម្តងទៀត។
- សួរវេជ្ជបណ្ឌិតសម្រាប់សំបុត្រពេទ្យ សម្រាប់ការងាររបស់អ្នក ប្រសិនបើអ្នកត្រូវការមួយច្បាប់។

**មតិយោបល់កែលម្អ ជួយយើងឱ្យបំពេញកិច្ចការប្រសើរជាងមុន។ សូមជួយយើង ដោយប្រាប់យើង អំពីការអញ្ជើញមករបស់អ្នកមកកាន់ ED។ ប្រើបែបបទ មតិយោបល់កែលម្អនៅក្នុង ED ឬនៅលើ គេហទំព័រ៖ www.monashhealth.org**

ខែកញ្ញា ឆ្នាំ 2021
អ្នកប្រើប្រាស់បានពិនិត្យឡើងវិញ